## សំណួរ

តើក្នុងករណីណា ដែលអ្នកប្រើប្រាស់ អាចប្រើប្រាស់ពូជដំណាំថ្មី ដោយមិនចាំបាច់មានការអនុញ្ញាត ពីអ្នកផលិត និងមិនទទួលខុសត្រូវចំពោះសំណាង?

## ចម្លើយ

ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឆ្នាំ ២០០៨ បានចែងការពារសិទ្ធិរបស់អ្នកបង្កាត់ ឬផលិតពូជ ដើម្បីជម្រុញការស្រាវជ្រាវ និងផ្តល់តម្លៃ ព្រមទាំងផលប្រយោជន៍ ដល់បុគ្គល ឬនីតិបុគ្គលដែលបានបង្កើតពូជថ្មី ទោះបីជាយ៉ាងនេះក្តី វិសាលភាពនៃការការពារ មានកម្រិតផងដែរ។ មាត្រា ១៦ នៃច្បាប់ដដែល បានចែងអំពីបញ្ហានេះ ដោយបញ្ជាក់ថា ការប្រើប្រាស់ក្នុងគោលបំណងពិសោធន៍ ឬ ការដាំសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងគ្មានបំណងធ្វើពាណិជ្ជកម្ម នឹងត្រូវបានអនុញ្ញាតដោយច្បាប់នេះ។ ដើម្បីកុំឲ្យមានការបំពាន ការកម្រិតនៃការការពារសិទ្ធិអ្នកផលិត ច្បាប់ចែងតម្រូវឲ្យក្រសួងឧស្សាហកម្ម និងក្រសួកសិកម្ម រួមគ្នាចែងនូវបទប្បញ្ញត្តិ ស្តីពី ការកម្រិតសិទ្ធិនៃម្ចាស់សិទ្ធិ។